ទីស្ដីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

លេខ ០២ រប-៨៥

# សាធារណរដ្ឋប្រជាមានិតកម្ពុជា

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

ភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៨៥

## សារាចរ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

-សមមិត្ត រដ្ឋអាជ្ញាអមតុលាការប្រជាជនខេត្ត-ក្រុង

**កម្មវត្ថុ** -សេចក្ដីណែនាំ ស្ដីពីការចេញសាលក្រមរឿងផ្ដាច់សមគ្គសង្វាសដោយការព្រមព្រៀងគ្នា ។

កន្លងមក ដោយបញ្ហាសង្គមតម្រូវ តុលាការប្រជាជន គ្រប់ខេត្ត-ក្រុង បានចេញដីកាសម្រេចទទួលស្គាល់ការឯកភាពលែងលះគ្នារវាងប្ដី និង ប្រពន្ធ ។ បទពិសោធន៍បានបង្ហាញអោយឃើញថា តម្លៃនដីកាសម្រេចនោះមិនទាន់មានលក្ខណៈសមស្រប់តាមខ្លឹមសារនៃចំណងអាពាហ៍ពិពាហ៍ដែលទាមទារតាមស្មារតី របស់រដ្ឋធម្មនុញ្ញ និងច្បាប់អោយមានសេចក្ដីសម្រេចមួយមានអនុភាពខ្ពស់ខាងគតិយុត្តិ ពីព្រោះការផ្ដាច់ចំណងអាពាហ៍ពិពាហ៍ សូម្បីក្នុងលក្ខណៈព្រមព្រៀងគ្នា ហើយឯកភាពគ្នាលើគ្រប់ចំណុចក៏ដោយ ពុំមែនគ្រាន់តែប៉ះពាល់ដល់ផលប្រយោជន៍ នឹងប្តាញាតិដែលកើតចេញពីរអាពាហ៍ពិពាហ៍ ដល់ទ្រព្យសម្បត្តិ និងកេរ្តិ៍មរតកទៀតផង ។

ក្នុងន័យនេះអំណើតទៅ ក្រសួងយុត្តិធម៌សូមសមមិត្តប្រធានតុលាការប្រជាជនគ្រប់ ខេត្ត-ក្រុង ឈប់ប្រើរូបមន្តដូចធ្លាប់បានធ្វើកន្លងមក ហើយចាត់វិធានការបើកការជំនុំជម្រះជាសាធារណៈតាមការណែនដូចតទៅ៖

១-ក្រោយពីធ្វើការផ្សះផ្សារវាងគូភាគីជាច្រើនលើកតាមលក្ខការណ៍សារាចរលេខ ០៤ សរច-៨៤ ចុះថ្ងៃទី៨ ខែកញ្ញាឆ្នាំ១៩៨៨ ក្នុងចំណុច ១ធំរួចហើយ គូភាគីមិនព្រមសះជា ដើម្បីរួមរស់ជាមួយគ្នា ហើយនៅតែចចេសក្នុងការព្រមព្រៀងលែងលះគ្នាដោយឯកភាពគ្នាលើគ្រប់ចំណុចដូចជាការគ្រប់គ្រងកូន ការចែកទ្រព្យសម្បត្តិរួម ការចិញ្ចឹមកូនជាដើម ចៅក្រមត្រូវធ្វើកំណត់ហេតុមួយស្ដី ពីលទ្ធផលនៃការផ្សះផ្សានៅក្នុងសៀវភៅកំណត់ហេតុផ្សះផ្សា ហើយចម្លងដាក់ចូលក្នុងសុំណុំរឿង រួចធ្វើរបាយការណ៍ជូនរឿងទៅតុលាការជំនុំជម្រះ ។ត្រង់នេះត្រូវយល់ថាការសុំលែងលះគ្នានោះ ធ្វើឡើងដោយគ្មានការបង្ខិតបង្ខំ និង ដោយស្ម័គ្រចិត្តពិតប្រាកដ ។ ផ្ទុយទៅវិញកាលបើឃើញថា ការបញ្ចេញឆន្ទៈនោះមានការបង្ខិតបង្ខំចៅក្រមមិនអាចយកឆន្ទៈផ្ទាល់របស់ខ្លួនទៅជំនួសឆន្ទៈរបស់គូភាគីបានឡើយ ។ ក្នុងករណីនេះចៅក្រមត្រូវធ្វើការអង្កេតស៊ើបសួរ តាមការណែនាំរបស់សារចបលខ០៤ សរច-៨៤ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៨៤ ដែលស្ដីក្នុងចំណុច១១ធំ ដើម្បីត្រៀមលក្ខណៈធ្វើរបាយការណ៍ជូនរឿងទៅតុលាការ ។ ក្រោយពីបានទទួលសំណុំរឿង ប្រធានតុលាការត្រូវចេញដីការចាត់តាំងចៅក្រមម្នាក់ ឬ ចាត់តាំងខ្លួនឯងធ្វើជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។ ក្រុមប្រឹក្សាជំនុំជម្រះ មានចៅក្រមម្នាក់ជាប្រធាន និងទីប្រឹក្សាប្រជាជនពីររូប ។

ដោយឡែកលេខាធិការ ក្រឡាបញ្ជីសវនាកា អាចអោយមានតែម្នាក់ ហើយទទួលភារកិច្ចដូចចែងក្នុងខ្លឹមសារនៃសារាចរលេខ០៤ សរច-៨៤ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៨៤ ។

២-អំពីការត្រៀមបម្រុងមុននឹងដាក់សំណុំរឿងជំនុំជម្រះ និងអំពីការងារនៅពេលសវនាការ ត្រូវគោរពតាមខ្លឹមសារនៃលក្ខការណ៍សារាចរលេខ០៤ សរច-៨៤ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៨៤ ដែលបានចែងក្នុងចំណុច III និង IV ធំ ។

៣-អំពីការតាក់តែងសាលក្រម ត្រូវផ្តិតយកតាមគំរូសាលក្រម ដែលក្រសួងយុត្តិធម៌បានតាក់តែងឡើង ហើយជូនភ្ជាប់ជាមួយសារាចរនេះ ដោយផ្អែកតាមអង្គហេតុជាក់ស្តែងនសុំណុំរឿងនីមួយៗ ។

ក្រសួងយុត្តិធម៌ មានកាតព្វកិច្ចទាញអារម្មណ៍ចំពោះសមមិត្តប្រធានតុលាការប្រជាជនគ្រប់ ខេត្ត-ក្រុង ថាៈ សេចក្តីណែនាំនេះ មានគោលដៅសម្រាប់វិនិច្ឆ័យចំពោះបណ្តឹងលេងលះដែលភាគីបានព្រមព្រៀងគ្នា ដោយសុទ្ធចិត្ត និង ឯកភាពគ្នាលើគ្រប់ចំណុចទាក់ទិន និងចំណងអាពាហ៍ពិពាហ៍ ។ តាមគោលការណ៍ ការជំនុំជម្រះត្រូវធ្វើឡើងចំពោះមុខគូក្តី ។ សាលក្រមមានអានុភាពអនុវត្តភ្លាមៗ ។ ក្នុងករណីនៃការជំនុំជម្រះដោយកំបាំងមុខគូភាគីណាមួយ សាលក្រមគ្មានអានុភាពអនុវត្តឡើយ ។ ក្នុងន័យខាងក្រោមនេះ គប្បីចំណាត់ការងារតាមខ្លឹមសារសារាចរលេខ ០៤ សរច-៨៤ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ១៩៨៤ ដែលមានចែងក្នុងកំណត់សម្គាល់ ។

ក្រសួងយុត្តិធម៌ សង្ឃឹមយ៉ាងមុតមាំថា សមមិត្តប្រធានតុលាការប្រជាជន គ្រប់ខេត្ត-ក្រុង នឹងយកចិត្តទុកដាក់អនុវត្តតាមសេចក្តីណែនាំនេះឲ្យបានត្រឹមត្រូវបំផុត ។

ហត្ថលេខា និងត្រា

**អ៊ុក ប៊ុនឈឿន**